ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៦៧ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## "ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច"សម្រាប់ការអនុវត្តសាកល្បងកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធនៅខេត្តកំពង់ស្ពឺ និងត្បូងឃ្មុំ

យោង ៖ - គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩
- គោលនយោបាយអប់រំក្រៅប្រព័ន្ធ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២
- គោលនយោបាយ ស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨
- ប្រកាសស្តីពីការអនុញ្ញាតឱ្យបោះពុម្ព និងប្រើប្រាស់សៀវភៅកម្មវិធីសិក្សាគោលសម្រាប់សមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦
- សេចក្តីណែនាំលេខ៤៣ អយក.សណន ស្តីពីកិច្ចដំណើរការកម្មវិធីអប់រំក្រៅប្រព័ន្ធ ចុះថ្ងៃទី១០ខែវិច្ឆិកា ឆ្នាំ២០១៦
- កិច្ចព្រមព្រៀងរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយអង្គការ GNI ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

ដើម្បីអនុវត្តកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធឱ្យមានប្រសិទ្ធភាព តាមរយៈការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចសម្រាប់កុមារ និងយុវជនក្រៅសាលា ក្នុងពេលប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំ ដូចខាងក្រោម ៖

**១- អាសយដ្ឋាន គេហទំព័រ និងទំព័រហ្វេសប៊ុក សម្រាប់បម្រើឱ្យការបង្រៀនពីចម្ងាយ ៖**

- នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានផលិតវីដេអូសម្រាប់ការរៀន និងការបង្រៀន ពីចម្ងាយចំនួន ២៨២ លើមុខវិជ្ជាចំនួន ១០ ដូចជា ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា)សិក្សាសង្គម(ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ) និងជំនាញមុខរបរ
- វីដេអូទាំងអស់ ត្រូវUpload ក្នុងអាសយដ្ឋាន គេហទំព័រ និងទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា៖
  - Facebook: https://www.facebook.com/krou.moeys.gov.kh/
  - YouTube: https://www.youtube.com/moeys
  - https://elearning.moeys.gov.kh

**២- រៀបចំចងក្រងនិងបង្កើតក្រុមការងារ Telegram ឬ Messenger ឬ WhatsApp ៖**

- នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ រៀបចំបង្កើតក្រុមការងារជាមួយមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដើម្បីពិនិត្យតាមដានការអនុវត្ត

- មន្ទីរអប់រំ យុវជន និងកីឡា រៀបចំបង្កើតក្រុមការងារជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក នីមួយៗ ដើម្បីពិនិត្យតាមដានការចុះឈ្មោះ និងការអនុវត្ត
- ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក រៀបចំបង្កើតក្រុមការងារជាមួយមន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ សង្កាត់ គ្រូបង្រៀន និងអ្នកដែលបានចុះឈ្មោះរៀនក្នុងកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ដើម្បីដំណើរការរៀន និងបង្រៀន
- អាចបង្កើតក្រុមការងារផ្សេងៗទៀតតាមការចាំបាច់របស់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ
- ឈ្មោះរបស់ក្រុមការងារនីមួយៗចាប់ផ្តើមដោយ NFE-LSEP បន្ទាប់មកឈ្មោះខេត្ត ឬឈ្មោះក្រុង ស្រុក។

**៣- មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុកៈ**

- បង្កើតក្រុមការងារទទួលខុសត្រូវ ដើម្បីអនុវត្ត "ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច"
- ផ្សព្វផ្សាយ និងជំរុញការអនុវត្ត"ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច" កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ឱ្យបានទូលំទូលាយ
- ត្រួតពិនិត្យការផ្តល់ និងប្រើប្រាស់សៀវភៅកម្មវិធីសិក្សាគោលសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ និងសៀវភៅសិក្សាគោលនៅគ្រប់ថ្នាក់ដើម្បីសម្របសម្រួលការរៀន និងបង្រៀន
- ផ្តល់ឯកសារ ឬ Copy Link មេរៀននៃកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ដែលក្រសួងបានផលិតនិងផ្សព្វផ្សាយ ទាំងឯកសាររឹង (Hardcopy) និងឯកសារទន់ (Softcopy) ទៅអ្នកពាក់ព័ន្ធតាមឋានានុក្រម
- ដោះស្រាយសំណូមពរ និងសំណើសុំ របស់ថ្នាក់រៀន និងបង្រៀនកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ទៅតាមសមត្ថភាព និងលទ្ធភាព
- រក្សាវិធានការអនាម័យសិក្សាជាប្រចាំ និងអនុវត្តតាមការណែនាំស្តីពីការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក។

**៤- មុខសញ្ញាអ្នករៀនក្នុងកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិៈ**

- មុខសញ្ញាអ្នករៀនជាកុមារ យុវជនស្ថិតនៅក្នុងគ្រួសារក្រីក្រ និងជួបការលំបាក ដែលគ្មានឱកាសបានរៀនសូត្រ និងសិស្សបោះបង់ការសិក្សាថ្នាក់ទី៧ ទី៨ និងទី៩ពីសាលាចំណេះទូទៅ និងកម្មករ កម្មការិនី ប្រជាពលរដ្ឋគ្រប់រូបដែលមានអាយុចាប់ពី១៤ឆ្នាំឡើងទៅ ដែលបានរៀនចប់ថ្នាក់អក្ខរកម្ម ឬបញ្ចប់កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ។

**៥- ការរៀបចំបើកដំណើរការថ្នាក់រៀនកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិៈ**

- អ្នករៀនអាចចុះឈ្មោះចូលរៀនក្នុងកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ដោយផ្ទាល់ជាមួយគ្រូបង្រៀនដែលជាអ្នកសម្របសម្រួលការរៀន និងបង្រៀន ឬចុះឈ្មោះចូលរៀន Online តាមរយៈប្រព័ន្ធគ្រប់គ្រងការសិក្សាពីចម្ងាយ(LMS)
- មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក រៀបចំឱ្យមានថ្នាក់ "ការសិក្សាពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិច"សម្រាប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ គ្រឹះស្ថានសិក្សា វត្តអារាម រោងចក្រ សហគ្រាសដែលអាចជួយសម្រួលដល់អ្នករៀនដែលបានចុះឈ្មោះចូលរៀន

**៦- គ្រូបង្រៀនកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ**

- គ្រូបង្រៀនកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ត្រូវបានជ្រើសរើសដោយមន្ទីរអប់រំ យុវជន

និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ជាគ្រូកិច្ចសន្យាដែលត្រូវ ជ្រើសរើសចេញពីគ្រូនៅតាមគ្រឹះស្ថានសាធារណៈ និងគ្រូជំនាញមុខរបរទាំងពីរភេទតាមលក្ខខណ្ឌដូចខាងក្រោម៖

  - គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ឬគ្រូអប់រំមូលដ្ឋាន
  - គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ
  - គ្រូបង្រៀនចូលនិវត្តន៍
  - គ្រូបង្រៀនជំនាញមុខរបរ។

- គ្រូបង្រៀនកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ មានភារកិច្ចបង្រៀនដោយផ្ទាល់ ឬសម្របសម្រួល ជាមួយអ្នករៀនតាមការណាត់ជួបពេលណាមួយ
- គ្រូបង្រៀនកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធណែនាំ និងរំឭកអំពីពេលវេលា ឬកាលវិភាគ ដែលត្រូវចូលរួមធ្វើតេស្តការសិក្សាពីចម្ងាយដល់អ្នករៀនដែលបានចុះឈ្មោះជាមួយខ្លួនផ្ទាល់
- ផ្តល់ព័ត៌មាន ឬស្នើសុំជំនួយពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក និងមន្ទីរអប់រំ យុវជន និងកីឡា សម្រាប់ដោះស្រាយបញ្ហាដែលកើតមានពេលដំណើរការកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ។

**៧- ការរៀន និងបង្រៀនកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ៖**

- អ្នករៀនអាចរៀនពីចម្ងាយតាមរយៈ Online ឬរៀនដោយផ្ទាល់ជាបណ្តុំជាមួយគ្រូនៅទីតាំង ឬថ្នាក់ ឬសាលាណាមួយដែលនៅជិតបំផុត
- អ្នករៀនត្រូវរៀនលើមុខវិជ្ជាចំនួន ១០ រួមមាន៖ ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា) សិក្សាសង្គម(ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ) និងជំនាញមុខរបរ
- គ្រូបង្រៀន និងអ្នករៀនប្រើប្រាស់សៀវភៅកម្មវិធីសិក្សាគោលសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ និងសៀវភៅសិក្សាគោលមធ្យមសិក្សាបឋមភូមិចំណេះទូទៅ
- អ្នករៀនត្រូវរៀនតាមរយៈវីដេអូសរុបចំនួន ២៨២។ ដោយឡែកអ្នករៀននៅថ្នាក់ឆ្នាំទី២ ត្រូវរៀនតែវីដេអូសរុបចំនួន ១៤០ ប៉ុណ្ណោះ
- អ្នករៀនពីចម្ងាយតាមរយៈ Online ត្រូវដោះស្រាយសំនួរ-លំហាត់តេស្តចំនួន ២ដង នៃមុខវិជ្ជានីមួយៗសម្រាប់ថ្នាក់ឆ្នាំទី១ និងចំនួន ២ដង នៃមុខវិជ្ជានីមួយៗសម្រាប់ឆ្នាំទី២។

**៨- ការប្រឡងបញ្ចប់ឆ្នាំសិក្សា និងចុះឈ្មោះប្រឡងសញ្ញាបត្រកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ៖**

**៨.១.ថ្នាក់ឆ្នាំទី១**

- អ្នករៀនថ្នាក់ឆ្នាំទី១ មានពិន្ទុតេស្តសរុបទាំងលើកទី១ និងទី២ជាប់មធ្យមភាគ ត្រូវបានឡើងថ្នាក់ឆ្នាំទី២។

**៨.២.ថ្នាក់ឆ្នាំទី២**

- អ្នករៀនពីចម្ងាយតាមរយៈ Online ត្រូវចូលរួមប្រឡងសញ្ញាបត្រកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ក្នុងទីតាំងថ្នាក់ ឬសាលាណាមួយដែលនៅជិតបំផុត ដែលខ្លួនបានចុះឈ្មោះប្រឡង
- អ្នករៀនពីចម្ងាយតាមរយៈ Online មានពិន្ទុតេស្តសរុបទាំងលើកទី១ និងទី២ជាប់មធ្យមភាគ អាចចុះឈ្មោះប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។

**៩- ការរៀបចំប្រឡងសញ្ញាបត្រ**

- មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក និងគ្រូបង្រៀនត្រូវទទួលខុសត្រូវរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ

- អ្នករៀនពីចម្ងាយតាមរយៈ Online នៃកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ត្រូវចូលរួមប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
- មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ត្រូវផ្ញើបញ្ជីលទ្ធផលប្រឡងជាប់ធ្លាក់មកក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ) បន្ទាប់ពីប្រកាសលទ្ធផលយ៉ាងយូរ១សប្តាហ៍។

**១០- សញ្ញាបត្រ និងកម្រិតសមមូលៈ**

- មន្ទីរអប់រំ យុវជន និងកីឡា ទទួលបន្ទុកចេញសញ្ញាបត្រជូនបេក្ខជននៃកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
- បេក្ខជននៃកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ ដែលបានប្រឡងជាប់អាចបន្តការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ។

**៧- ការពិនិត្យតាមដាន និងវាយតម្លៃ ៖**

- មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក មន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ សង្កាត់ និងគ្រូបង្រៀន ត្រូវពិនិត្យតាមដានការរៀន និងបង្រៀននៃកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធក្នុងមូលដ្ឋានរបស់ខ្លួន និងធ្វើរបាយការណ៍ជូនតាមឋានានុក្រម
- នាយកដ្ឋានអប់រំក្រៅប្រព័ន្ធត្រូវពិនិត្យតាមដាន និងសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក លើការសម្របសម្រួលជួយដល់គ្រូបង្រៀន និងអ្នករៀននៃកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ។

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ និងត្បូងឃ្មុំ ទទួលបានសេចក្តីណែនាំនេះ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអនុវត្តដោយស្មារតីទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ៧ [illegible]កើត ខែ បុស្ស ឆ្នាំជូត ឯកស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល**

- នាយកដ្ឋានពាក់ព័ន្ធ «ដើម្បីជ្រាបជាព័ត៌មាន»
- សាលាខេត្តកំពង់ស្ពឺ និងត្បូងឃ្មុំ «ដើម្បីជូនជ្រាប»
- មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក នៃខេត្តកំពង់ស្ពឺ និងត្បូងឃ្មុំ «ដើម្បីអនុវត្ត»
- កាលប្បវត្តិ ឯកសារនា.អកប